**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**អគ្គនាយកដ្ឋានការងារ**
**នាយកដ្ឋានអធិការកិច្ចការងារ**

# កំ ណ ត់ ហេ តុ

## ស្តីពីការសាកសួរព័ត៌មានពីតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ខេវីធី អ៊ីអិមប៊ី បេស (ខេមបូឌា) ៦.ក

ឆ្នាំពីរពាន់ម្ភៃប្រាំ ខែមេសា ថ្ងៃទីដប់ប្រាំបី វេលាម៉ោងដប់បួន និងសែសិបនាទីរសៀល នៅការិយាល័យ នៃក្រុមហ៊ុន មានបើកកិច្ចប្រជុំ សាកសួរព័ត៌មានស្តីពីការព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុនមួយរយៈគឺ៥២ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥ លើកម្មករនិយោជិតចំនួន ១៥នាក់ (ស្រី ១០នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១៦នាក់ (ស្រី ១០នាក់) ។ ក្នុងនោះមានសហជីពចំនួន **គ្មាន** មានបញ្ជិកា ហើយនៅមាន សុពលភាពចំនួន **គ្មាន**។

ក្រោមអធិបតីភាពរបស់ **លោក វង់ ពេជ្ររតនៈ** ជាប្រធានការិយាល័យអធិការកិច្ច និងសន្តិសុខការងារទី៣ នៃនាយកដ្ឋានអធិការកិច្ចការងារ តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

### <u>អញ្ជើញចូលរួមក្នុងឱកាសនោះ រួមមាន</u>៖

១- <u>**ខាងតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**</u>

**លោកស្រី ង៉ែត លីណា មន្ត្រីការិយាល័យអធិការកិច្ច និងសន្តិសុខការងារទី៣**

២- <u>**ខាងតំណាងកម្មករនិយោជិតមាន:**</u>

លោក ស៊ាន គា ប្រតិភូបុគ្គលិក

### <u>យោបល់របស់តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ</u>

ជាកិច្ចចាប់ផ្តើម **លោក វង់ ពេជ្ររតនៈ** ជាប្រធានអង្គប្រជុំបានថ្លែងអំណរគុណដល់តំណាងបងប្អូនកម្មករនិយោជិតទាំងអស់ដែលបានអញ្ជើញចូលរួមផ្តល់ព័ត៌មានបំភ្លឺស្តីពីការព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុនមួយរយៈនាពេលខាងមុខ។ បន្ទាប់មក **លោកប្រធានអង្គប្រជុំ** ក៏បានសាកសួរព័ត៌មានផ្សេងៗបន្ថែមទៀតស្តីពីការសុំព្យួរកិច្ចការងាររបស់ក្រុមហ៊ុនចំពោះតំណាងបងប្អូនកម្មករនិយោជិត និងអត្ថប្រយោជន៍ក្នុងរយៈពេលព្យួរ។

**<u>យោបល់របស់តំណាងកម្មករនិយោជិត:</u>**

ឆ្លើយតបនឹងប្រសាសន៍របស់**លោកប្រធានអង្គប្រជុំ** តំណាងបងប្អូនកម្មករនិយោជិតនៃក្រុមហ៊ុនបានផ្តល់ព័ត៌មានយ៉ាងល្អិតល្អន់ដូចតទៅ:

បានពិនិត្យឃើញថា បច្ចុប្បន្នក្រុមហ៊ុនមិនមានការបញ្ជាទិញដែលបណ្តាលឱ្យប្រវាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុដូចនេះ ក្រុមហ៊ុនបានស្នើសុំព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៥នាក់ (ស្រី ១០នាក់) រយៈពេល ៥២ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥។ ហើយក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ តំណាងកម្មករនិយោជិតបានប្រជុំជាមួយតំណាងក្រុមហ៊ុនស្តីពីការព្យួរកិច្ចសន្យាការងារនៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៥ និងបានឯកភាពការព្យួរកិច្ចសន្យាការងាររយៈពេល ៥២ថ្ងៃ តាមសំណើរបស់ក្រុមហ៊ុន ហើយបានឯកភាពព្រមព្រៀងគ្នាទទួលយកអត្ថប្រយោជន៍ដូចខាងក្រោម៖

-ប្រាក់ឧបត្ថម្ភ ៦០ដុល្លារ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ហើយក្រុមហ៊ុននឹងបើកផ្តល់ជូនកម្មករនិយោជិតនៅថ្ងៃទី១០ នៃខែបន្ទាប់ទៅតាមចំនួនដែលត្រូវទទួលបានក្នុងខែនីមួយៗដូចមានចែងក្នុងកិច្ចព្រមព្រៀង។

-ការឈប់សម្រាកប្រចាំឆ្នាំក្រុមហ៊ុនបានអនុវត្តសមស្របតាមច្បាប់ស្តីពីការងារ។

-ក្រុមហ៊ុនបានអនុវត្តការបើកប្រាក់អតីតភាពការងារជូនកម្មករនិយោជិត។

-ក្រុមហ៊ុន និងតំណាងកម្មករនិយោជិត បានធ្វើកិច្ចព្រមព្រៀងជាមួយគ្នា នឹងបានឯកភាពការព្យួរកិច្ចសន្យាការងារ (ដូចមានលិខិតភ្ជាប់ជាមួយ)។

-ក្រោយបញ្ចប់ការព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុនសន្យាថានឹងឱ្យកម្មករនិយោជិតចូលបម្រើការងារធម្មតាវិញហើយរក្សាតួនាទីភារកិច្ចរបស់កម្មករនិយោជិតនៅដដែល។

កិច្ចប្រជុំនេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ប្រាំមួយ និងសែសិបប្រាំនាទីរសៀលនាថ្ងៃ ខែ ឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៥

**បានឃើញ និងឯកភាព**
**ប្រធានអង្គប្រជុំ**

**វង់ ពេជ្ររតនៈ**

**បានឃើញ និងឯកភាព**
**អ្នកផ្តល់ព័ត៌មាន**

**ស៊ាន គា**

**អ្នកកត់ត្រា**

**ង៉ែត លីណា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**អគ្គនាយកដ្ឋានការងារ**
**នាយកដ្ឋានអធិការកិច្ចការងារ**

# កំ ណ ត់ ហេ តុ

## ស្តីពីការសាកសួរព័ត៌មានពីតំណាងនិយោជកនៃក្រុមហ៊ុន ខេវីធី អ៊ីអិមប៊ី បេស (ខេមបូឌា) ៦.ក

ឆ្នាំពីរពាន់ម្ភៃប្រាំ ខែមេសា ថ្ងៃទីដប់ប្រាំបី វេលាម៉ោងដប់បួន និងសាមសិបនាទីរសៀល នៅការិយាល័យនៃក្រុមហ៊ុន មានបើកប្រជុំសាកសួរព័ត៌មានស្តីពីការព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុនដោយគិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥ រហូតដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥ លើកម្មករនិយោជិតចំនួន ១៥នាក់ (ស្រី ១០នាក់) រយៈពេល ៥២ថ្ងៃ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១៦នាក់ (ស្រី ១០នាក់) ដែលស្ថិតក្នុងកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ចំនួន ១៦នាក់ (ស្រី ១០នាក់) ។

ក្រោមអធិបតីភាពរបស់ **លោក វង់ ពេជ្ររតនៈ** ជាប្រធានការិយាល័យអធិការកិច្ច និងសន្តិសុខការងារទី៣ នៃនាយកដ្ឋានអធិការកិច្ចការងារ តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

### <u>អញ្ជើញចូលរួមក្នុងឱកាសនោះ រួមមាន៖</u>

១- <u>ខាងតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ</u>
លោកស្រី ង៉ែត លីណា មន្ត្រីការិយាល័យអធិការកិច្ច និងសន្តិសុខការងារទី៣
២- <u>ខាងតំណាងនិយោជកមាន៖</u>
លោកស្រី នួន សូហ្វីយ៉ា នាយកក្រុមហ៊ុន

### <u>យោបល់របស់តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ</u>

ជាកិច្ចចាប់ផ្តើម **លោក វង់ ពេជ្ររតនៈ** ប្រធានអង្គប្រជុំបានថ្លែងអំណរគុណដល់ **លោកស្រីជាតំណាងក្រុមហ៊ុន** ដែលបានអញ្ជើញចូលរួមផ្តល់ព័ត៌មានបំភ្លឺស្តីពីការព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុនមួយរយៈនាពេលខាងមុខ។ បន្ទាប់មក **លោកប្រធានអង្គប្រជុំ** ក៏បានសាកសួរព័ត៌មានផ្សេងៗបន្ថែមទៀតស្តីពីការសុំព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុន។

**<u>យោបល់របស់តំណាងនិយោជក៖</u>**

ឆ្លើយតបនឹងប្រសាសន៍របស់ **លោកស្រីប្រធានអង្គប្រជុំ** តំណាងក្រុមហ៊ុនបានផ្តល់ព័ត៌មានបំភ្លឺដូចតទៅ:

ក្រុមហ៊ុនគ្មានអ្នកបញ្ជាទិញដែលបណ្តាលឱ្យច្រវាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុនេះ ក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៥នាក់ (ស្រី ១០នាក់) រយៈពេល ៥២ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥។ ហើយក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុនបានប្រជុំជាមួយតំណាងកម្មករនិយោជិតស្តីពីការព្យួរកិច្ចសន្យាការងារ ហើយព្រមព្រៀងគ្នាដោយខាងក្រុមហ៊ុនផ្តល់អត្ថប្រយោជន៍ជូនកម្មករនិយោជិតដូចខាងក្រោម៖

-ក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភ ៦០ដុល្លារ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ហើយក្រុមហ៊ុននឹងបើកផ្តល់ជូនកម្មករនិយោជិតនៅថ្ងៃទី១០ នៃខែបន្ទាប់ទៅតាមចំនួនដែលត្រូវទទួលបានក្នុងខែនីមួយៗដូចមានចែងក្នុងកិច្ចព្រមព្រៀង។

-ការឈប់សម្រាកប្រចាំឆ្នាំ ក្រុមហ៊ុនបានអនុវត្តសមស្របតាមច្បាប់ស្តីពីការងារ។

-ក្រុមហ៊ុនបានអនុវត្តការបើកប្រាក់អតីតភាពជូនកម្មករនិយោជិត។

-ក្រុមហ៊ុន និងតំណាងកម្មករនិយោជិតបានធ្វើកិច្ចព្រមព្រៀងជាមួយគ្នា នឹងបានឯកភាពការព្យួរកិច្ចសន្យាការងារ (ដូចមានលិខិតភ្ជាប់ជាមួយ)។

-ក្រោយបញ្ចប់ការព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុនសន្យាថានឹងឱ្យកម្មករនិយោជិតចូលបម្រើការងារជាធម្មតាវិញ ហើយរក្សាតួនាទីភារកិច្ចរបស់កម្មករនិយោជិតនៅដដែល។

កិច្ចប្រជុំនេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ប្រាំពីរ និងដប់នាទី នាថ្ងៃ ខែ ឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៥

| **បានឃើញ និងឯកភាព**<br>**ប្រធានអង្គប្រជុំ** | **បានឃើញ និងឯកភាព**<br>**អ្នកផ្តល់ព័ត៌មាន** | **អ្នកកត់ត្រា** |
|---|---|---|
| **វង់ ពេជ្ររតនៈ** | **នួន សូហ្វីយ៉ា** | **ង៉ែត លីណា** |

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អគ្គនាយកដ្ឋានការងារ**

**នាយកដ្ឋានអធិការកិច្ចការងារ**

# បញ្ជីវត្តមាន

តំណាងកម្មករនិយោជិត ប្រតិភូបុគ្គលិក និងសហជីពប្រចាំសហគ្រាស គ្រឹះស្ថាន៖......................................

......ខេវីធី អ៊ីអឹមប៊ី បេស (ខេមបូឌា) ឯ.ក......................................................................

ជួបជាមួយក្រុមអធិការកិច្ចការងារទី.........នៅថ្ងៃទី...១៨....ខែ...មេសា... ឆ្នាំ២០២៤ វេលាម៉ោង...១៤:៥០ នាទី

| ល.រ | គោត្តនាម និងនាម | ភេទ | មុខងារ | ប្រតិភូបុគ្គលិក/សហជីព | លេខទូរស័ព្ទ | ហត្ថលេខា |
|---|---|---|---|---|---|---|
| ១ | សារិន ធា | ប | ប្រធានក្រុម | ប្រតិភូបុគ្គលិក. | 0977220745 | SK. |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ខេវីធី អ៊ីអឹមប៊ី បេស (ខេមបូឌា) ឯ.ក
KVT EMB BEST (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA



*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ក្រុមហ៊ុន KVT EMB BEST (CAMBODIA) CO., LTD. KINGDOM OF CAMBODIA

- បានបញ្ចប់ត្រឹមលេខរៀង............
- ជួបប្រតិភូបុគ្គលិក និងសហជីព ដោយមានរដ្ឋបាល ☐ គ្មានរដ្ឋបាល ☐
- ចុះសាកសួរព័ត៌មានកម្មករនិយោជិតក្នុងផលិតកម្ម ដោយមានរដ្ឋបាល ☐ គ្មានរដ្ឋបាល ☐